អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ

# សេចក្តីថ្លែងការណ៍រួម
# អង្គការពលកម្មអន្តរជាតិ និង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា

## អង្គការសហប្រជាជាតិស្វាគមន៍ការស៊ើបអង្កេតឡើងវិញ ករណីឃាតកម្មលើប្រធានសហជីពកម្មករ

*១៨ សីហា ២០០៨* - ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) និងអង្គការពលកម្មអន្តរជាតិ(ILO) ស្វាគមន៍ការសំរេចរបស់សាលាឧទ្ធរណ៍នៅថ្ងៃម្សិលមិញ បង្គាប់ឲ្យបន្តធ្វើការស៊ើបអង្កេតករណីឃាតកម្មលើលោក ជា វិជ្ជា ប្រធានសហជីពកម្មករ ។ ពេលនេះ វាហាក់ដូចជាគ្មានការមន្ទិលសង្ស័យទេ ព្រោះមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីតំកល់ការចោទប្រកាន់លើ ប៊ន សំណាង និងសុខ សំអឿន ។ ការកាត់ទោសពីដំបូងលើបុរសពីរនាក់នេះពីបទឃាតកម្ម ត្រូវបានរិះគន់ជាខ្លាំង ដោយសារតុលាការផ្អែកតែលើចំលើយសារភាពដែលបានមកពីការបង្ខិតបង្ខំ គ្មានភស្តុតាងច្បាស់លាស់ប្រឆាំងនឹងបុរសពីរនាក់នេះ និងការមិនទទួលយកសក្ខីកម្មរបស់សាក្សីដែលបញ្ជាក់ថាបុរសទាំងពីរនាក់នេះមិនបានប្រព្រឹត្តបទល្មើស ។ ឥឡូវនេះ គេគួរតែលើកលែងការចោទប្រកាន់បុរសទាំងពីរនាក់នេះ ទុកឲ្យនគរបាលធ្វើការស្រាវជ្រាវរកអ្នកទទួលខុសត្រូវពិតប្រាកដក្នុងការបាញ់សំលាប់លោក ជា វិជ្ជា ក្នុងខែមករា ឆ្នាំ២០០៤ ។

ករណីនេះបានចោទជាបញ្ហាយ៉ាងច្រើនអំពីសមត្ថភាពនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ស្របតាមបទដ្ឋានអន្តរជាតិ និងឆន្ទៈរបស់អាជ្ញាធរក្នុងការប្រយុទ្ធប្រឆាំងនឹងការសំលាប់ក្រៅច្បាប់ និងនីទណ្ឌភាព ។ ការខុសឆ្គងនៃប្រព័ន្ធយុត្តិធម៌ទៅលើ ប៊ន សំណាង និង សុខ សំអឿន បានបណ្តោយឲ្យឃាតករពិតប្រាកដ គេចផុតពីសំណាញ់ច្បាប់រយៈពេលជាងប្រាំឆ្នាំហើយ ។ នៅពេលជាមួយគ្នានេះដែរ ការិយាល័យសិទ្ធិមនុស្ស(OHCHR) និងអង្គការពលកម្មអន្តរជាតិ(ILO) ស្នើឲ្យតុលាការសើរើការកាត់សេចក្តីលើ ថាច់ សាវេត ករណីឃាតកម្មលើ រស់ សុវណ្ណារ៉េត ដោយសារករណីនេះមានមូលហេតុគួរឲ្យជឿជាក់បានដូចគ្នា ទាក់ទងនឹងសុវត្ថិភាពនៃការកាត់ទោស ។

បណ្តាស្ថាប័នអន្តរជាតិ រួមទាំងគណៈកម្មាធិការអ្នកជំនាញនៃអង្គការពលកម្មអន្តរជាតិ(ILO) និងគណៈកម្មាធិការទទួលបន្ទុកសេរីភាពនៃការបង្កើតសមាគម ហើយនៅពេលថ្មីៗបំផុតនេះ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរិះគន់ចំពោះការឆ្លើយតបរបស់អាជ្ញាធរកម្ពុជាចំពោះឃាតកម្មលើប្រធានសហជីពកម្មករបីនាក់នៅកម្ពុជាកាលពីឆ្នាំកន្លងទៅថ្មីៗនេះ ។

អនុលោមតាមអនុសាសន៍របស់ស្ថាប័នអន្តរជាតិទាំងនេះ អង្គការពលកម្មអន្តរជាតិ(ILO) និងការិយាល័យសិទ្ធិមនុស្ស(OHCHR) ពេលនេះ សូមស្នើយ៉ាងទទូចឲ្យអាជ្ញាកម្ពុជាធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ប្រកបដោយតម្លាភាព និងដោយឯករាជ្យ ដើម្បីកំណត់ឃាតករពិតប្រាកដដែលសំលាប់លោក ជា វិជ្ជា លោក រស់ សុវណ្ណារ៉េត និង លោក ហ៊ី វុទ្ធី ។ ការស៊ើបអង្កេតឲ្យបានឆាប់រហ័ស និងមិនលំអៀងលើករណីទាំងនេះ មានសារៈសំខាន់ណាស់ដើម្បីទប់ស្កាត់ការសំលាប់ ដែលនាំឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍នៃសហជីពកម្មករ ។

គេសង្ឃឹមថា ចំណាត់ការរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃម្សិលមិញនេះ បង្ហាញពីការខិតខំប្រឹងប្រែងជាថ្មីដោយអាជ្ញាធរកម្ពុជា ក្នុងការបញ្ចប់និទណ្ឌភាពនៅកម្ពុជា និងត្រួសត្រាយផ្លូវសំរាប់សហជីពកម្មករឯករាជ្យ តំណាងសហជីព និងសហជីពកម្មករដែលមានការទទួលខុសត្រូវ ដើម្បីការអភិវឌ្ឍន៍ នៅក្នុងប្រទេស ។

ចប់

*សារតា ៖*

## និទណ្ឌភាព និងអំពើអយុត្តិធម៌នៅតែបន្តមានចំពោះការសំលាប់ប្រធានសហជីពកម្មករ

ឃាតកម្មលើ ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC) ទាំងថ្ងៃ នៅកណ្តាលរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ បាន និងបន្តឲ្យមានការភ័យខ្លាចដល់ការអនុវត្តន៍សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការសំដែងមតិនៅកម្ពុជា ។ ការឆ្លើយតបរបស់តុលាការ និងនគរបាលចំពោះឃាតកម្មនេះ បានធ្វើឲ្យមានវាទប្បដិវាទដែលបន្តមានរហូតមកទល់ថ្ងៃនេះ ធ្វើឲ្យអន្តរាយដល់នីតិរដ្ឋនៅកម្ពុជា ពង្រឹងវប្បធម៌និទណ្ឌភាព និងធ្វើឲ្យសាធារណៈជនបាត់បង់ការជឿទុកចិត្តថែមទៀតលើប្រព័ន្ធយុត្តិធម៌ដែលកំពុងតែទន់ខ្សោយស្រាប់ ។ ម្យ៉ាងវិញទៀត អាជ្ញាធរបានប្រព្រឹត្តខុសជាបន្តបន្ទាប់ពីការមិនព្រមរកយុត្តិធម៌ឲ្យជនរងគ្រោះ ក្នុងការចោទមនុស្សខុសចំពោះករណីឃាតកម្មទាំងនេះ ដែលពេលនេះឃាតករពិតប្រាកដ មិនទាន់ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសនៅឡើយ ។

## ករណីទីមួយ ៖ ការផ្តន្ទាទោស ប៊ន សំណាង និង សុខ សំអឿន ពីបទឃាតកម្មលើ ជា វិជ្ជា

សាលាដំបូងក្រុងភ្នំពេញ បានកាត់ទោសបុរសពីរនាក់គឺ ប៊ន សំណាង និងសុខ សំអឿន ពីបទឃាតកម្ម បន្ទាប់ពីការស៊ើបអង្កេតមិនបានល្អរបស់នគរបាល ។ មានហេតុផលយ៉ាងរឹងមាំសង្ស័យពីសុពលភាពនៃការកាត់ទោសនេះ ។ ចៅក្រមស៊ើបអង្កេតដំបូង បានលើកលែងការចោទ

ប្រកាន់នេះ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែចៅក្រមនោះត្រូវបានដកចេញ ហើយរឿងក្តីនេះ ត្រូវបានបង្វិលឲ្យជំនុំជម្រះ។ បុរសទាំងពីរនាក់នេះ ត្រូវបានផ្តន្ទាទោស ដោយផ្អែកលើចំលើយសារភាពដែលខ្លួនបានដកយកវិញ ដោយមិនពិចារណាពីចំលើយរបស់សាក្សីចុងចោទ និងភស្តុតាងដែលបញ្ជាក់ថា បុរសទាំងពីរនោះ អាចមិនមែនជាអ្នកទទួលខុសត្រូវនោះទេ។ លោកហេង ពៅ ដែលជាមេប៉ូលីសដឹកនាំការស៊ើបអង្កេតនេះ តាំងពីពេលនោះមក ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារជាច្រើនបទល្មើស ពីបទឃាតកម្ម គៃបន្លំ និងការបំភិតបំភ័យ ។

ក្នុងខែមេសា ឆ្នាំ២០០៧ សាលាឧទ្ធរណ៍បានតំកល់ការផ្តន្ទាទោសនេះ និងបានបញ្ជាក់ពីការដាក់ទោសគុក ២០ឆ្នាំ ដោយមិនគិតពីភាពចន្លោះប្រហោងរបស់សាលាដំបូងឡើយ ។

ក្នុងខែមិថុនា ឆ្នាំ២០០៨ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស តាមរយៈការិយាល័យរបស់លោកស្រីនៅកម្ពុជា បានដាក់ជូនតុលាការកំពូលនូវសារណាប្រឹក្សាយោបល់មួយ ក្នុងនាមជាមិត្តរបស់តុលាការ គឺជាឯកសារវិភាគផ្លូវច្បាប់ ដោយទាញឲ្យមានចំណាប់អារម្មណ៍ដល់ការបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិជាសារវន្តមួយចំនួន ដោយតុលាការជាន់ទាប ។[1]

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ តុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា បានបង្គាប់ឲ្យដោះលែង ប៊ន សំណាង និងសុខ សំអឿន ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែពួកគេនៅតែស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ។ ការដោះលែងបណ្តោះអាសន្នរបស់ពួកគេ ត្រូវបានស្វាគមន៍ ដោយអង្គការពលកម្មអន្តរជាតិ(ILO) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ថាជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកការធានាសុវត្ថិភាព ដល់ថ្នាក់ដឹកនាំសហជីពកម្មករនានា និងលើកកំពស់សិទ្ធិសេរីភាពនៃការបង្កើតសមាគមនៅកម្ពុជា ។ សាលាឧទ្ធរណ៍ ត្រូវបានបង្គាប់ឲ្យពិនិត្យរឿងក្តីនេះឡើងវិញ ។

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ សាលាឧទ្ធរណ៍បានបើកសវនាការខ្លីមួយ ដើម្បីបង្គាប់ជាផ្លូវការឲ្យបើកការស៊ើបអង្កេតឡើងវិញអំពីករណីប្រឆាំងនឹងប៊ន សំណាង និងសុខ សំអឿន នេះ។ សាលាឧទ្ធរណ៍ក៏សំរេចឲ្យនៅក្រៅឃុំបណ្តោះអាសន្នបន្តទៀតផងដែរ ។

[1] ក្នុងខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេចថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដោយសារសន្ធិសញ្ញាទាំងនេះ ត្រូវបានធានាការពារដោយមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ថាជាផ្នែកមួយនៃច្បាប់កម្ពុជា ។ ដូច្នេះតុលាការកំពូល ក៏ដូចជាតុលាការទាំងអស់នៅកម្ពុជា មានកាតព្វកិច្ច ធានាការគោរពបញ្ញត្តិស្តីពីការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងក្នុងសន្ធិសញ្ញានានា ហើយការអនុវត្តខុសឆ្គងរបស់តុលាការជាន់ទាបត្រូវតែមានការកែតម្រូវ ។

## ករណីទីពីរ ៖ ការផ្តន្ទាទោស ថាច់ សាវេត ពីបទឃាតកម្មលើ រស់ សុវណ្ណារ៉េត

រស់ សុវណ្ណារ៉េត ជាប្រធានសហជីពសេរីកម្មករនៃរោងចក្រកុមារាទ្រីនុងហ្គាល ត្រូវបានបាញ់សំលាប់ ដោយបុរសពីរនាក់ជិះម៉ូតូមួយគ្រឿងនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៤ ។ ឃាតកម្មនេះ បានកើតមានក្នុងរយៈមិនដល់បួនខែផង បន្ទាប់ពីឃាតកម្មស្រដៀងគ្នានេះលើ ជា វិជ្ជា ។ ក្នុងខែកម្ភៈ ឆ្នាំ២០០៥ ថាច់ សាវេត ត្រូវបានរកឃើញថាមានពិរុទ្ធភាព ពីបទឃាតកម្មលើ រស់ សុវណ្ណារ៉េត ប្រធានសហជីពកម្មករ កាលពីខែឧសភា ឆ្នាំ២០០៤ ។ ភាពមិនប្រក្រតីស្រដៀងគ្នានេះ កើតមានក្នុងការស៊ើបអង្កេតដោយនគរបាល ដែលការស៊ើបអង្កេតនេះបានដឹកនាំដោយលោក ហេង ពៅ ដដែល។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ សាលាឧទ្ធរណ៍ បានតំកល់ការកាត់សេចក្តីថាច់ សាវេត របស់សាលាដំបូងក្រុងភ្នំពេញ។ រឿងក្តីនេះ គឺជាកញ្ចក់ឆ្លុះរូបភាពស្រដៀងគ្នានឹងករណីប៊ិន សំណាង និងសុខ សំអឿន ។ អង្គការពលកម្មអន្តរជាតិ(ILO) បានសំដែងក្តីសង្ឃឹមយ៉ាងមុតមាំជាសាធារណៈថា បណ្តឹងសាទុក្ខ នឹងត្រូវបញ្ជូនទៅតុលាការកំពូលយ៉ាងឆាប់ដើម្បីសំរេចឲ្យមានការដោះលែង ថាច់ សាវេត ។

## ករណីទីបី ៖ ករណីឃាតកម្មលើ ហ៊ី វុទ្ធី ដែលនៅមិនទាន់ដោះស្រាយ

ហ៊ី វុទ្ធី ជាប្រធានសហជីពសេរីកម្មករនៃរោងចក្រសាន់តិចត្រូវបានគេបាញ់សំលាប់ នៅពេលគាត់ធ្វើដំណើរតាមផ្លូវពីកន្លែងធ្វើការទៅផ្ទះ នៅថ្ងៃទី២៤ ខែកម្ភៈ ឆ្នាំ២០០៧ ។ ការស៊ើបអង្កេតរបស់នគរបាលខកខាន មិនបានធ្វើឲ្យមានការរីកចំរើនណាមួយនោះទេ ហើយក្រោយមក ជាយថាហេតុ បានបិទការស៊ើបអង្កេតនេះទៅ ។ ឃាតករនៅតែមិនទាន់ត្រូវបានចាប់ខ្លួននៅឡើយ ។

## *ការឆ្លើយតបរបស់អង្គការសហប្រជាជាតិ*

ការសំលាប់ និងការគំរាមកំហែងនានា ធ្លាប់ត្រូវបានលើកឡើងដោយស្ថាប័នត្រួតពិនិត្យរបស់ ILO ។ អង្គការ ILO បានបំពេញបេសកកម្មផ្ទាល់មកប្រទេសកម្ពុជា ក្នុងខែមេសា ឆ្នាំ២០០៨ ។ បេសកកម្មនេះ បានសន្និដ្ឋានថា តុលាការកម្ពុជាជួបប្រទះបញ្ហាធ្ងន់ធ្ងរអំពីសមត្ថភាព និងការខ្វះឯករាជ្យភាព ដែលការផ្តន្ទាទោស ប៊ន សំណាង និងសុខ សំអឿន ត្រូវបានធ្វើឡើងក្នុងការជំនុំជម្រះក្តីដោយមានភាពមិនប្រក្រតីខាងនីតិវិធី រួមទាំងការបដិសេធ មិនទទួលយកភស្តុតាងនៃភាពសុចរិតរបស់ពួកគេ ហើយរដ្ឋាភិបាលមិនបានចាត់វិធានការច្បាស់លាស់ណាមួយ ដើម្បីធានាឲ្យមានការពិនិត្យឡើងវិញនូវករណីទាំងនេះប្រកបដោយអត្តន័យ និងដោយឯករាជ្យនោះទេ ។ គួរកត់សំគាល់ផងដែរថា មិនមានការរីកចំរើនក្នុងការស៊ើបអង្កេតករណីហ៊ី វុទ្ធី ទេ ។ ការសន្និដ្ឋានទាំងនេះ ស្របគ្នានឹងការសន្និដ្ឋានស្រដៀងគ្នា របស់តំណាងពិសេសទាំងពីររូបកន្លងមកនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា គឺលោក ភីថឺ ល័យប្រេក និងលោកសាស្ត្រាចារ្យ យ៉ាស់ ហ្គាយ នៅក្នុងរបាយការណ៍ជាច្រើនរបស់ពួកគាត់ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស និងជូនអតីតគណៈកម្មការសិទ្ធិមនុស្ស ។[2]

គណៈកម្មាធិការនៃអង្គការ ILO ទទួលបន្ទុកសេរីភាពនៃសមាគម ក្នុងរបាយការណ៍របស់ខ្លួនលើកទី៣៥១ បានគូសបញ្ជាក់ជាថ្មីពីការរកឃើញរបស់បេសកកម្មនេះថា រដ្ឋាភិបាលមិនបានចាត់វិធានការច្បាស់លាស់ដើម្បីធានាឲ្យមានការពិនិត្យឡើងវិញនូវករណីទាំងនេះប្រកបដោយអត្តន័យ និងដោយឯករាជ្យនោះទេ ហើយបានរកឃើញថារដ្ឋាភិបាលខកខានមិនបានអនុវត្តអនុសាសន៍ជាច្រើនរបស់គណៈកម្មាធិការនេះ (កថាខណ្ឌទី ២៥២)

ក្នុងខែឧសភា ឆ្នាំ២០០៩ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួនស្តីពីរបាយការណ៍ដំបូងរបស់កម្ពុជាក្នុងការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានភ្ជាប់ខ្លួនទៅនឹងរបាយការណ៍ស្វែងរកការពិត និងអនុសាសន៍របស់អង្គការILO ហើយបានស្នើយ៉ាងទទូចឲ្យរដ្ឋាភិបាលធានាថា សមាជិកសហជីពកម្មករទាំងអស់ អាចអនុវត្តសិទ្ធិរបស់ខ្លួនដោយគ្មានការភ័យខ្លាច និងគ្មានការបំភិតបំភ័យ ។

---

[2] សូមមើលឧទាហរណ៍E/CN.4/2005/116, para. 22 et seq; E/CN.4/2006/110; A/HRC/4/36, para.44; A/HRC/7/42, para. 56. សូមមើលផងដែរនូវរបាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការ “Continuing patterns of impunity” ដែលមាននៅលើវិបសាយរបស់ការិយាល័យ OHCHR Cambodia: http://cambodia.ohchr.org.